# កិច្ចព្រមព្រៀង
# ស្តីពី
# ដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

- ដោយយល់ឃើញថា ដំណោះស្រាយដោយសន្តិវិធីតាមរយៈការចរចា គឺជាមធ្យោបាយដ៏ល្អតែមួយគត់ក្នុងការដោះស្រាយបញ្ហានយោបាយដែលកើតមាន ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ នៃរដ្ឋសភា នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣
- ដោយគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងដើម្បីជាផលប្រយោជន៍ដ៏ឧត្តុងឧត្តមនៃប្រទេសជាតិ

ថ្នាក់ដឹកនាំកំពូលនៃ **គណបក្សប្រជាជនកម្ពុជា** និង **គណបក្សសង្គ្រោះជាតិ** បានជួបប្រជុំពិភាក្សាគ្នា នាថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ នៅវិមានព្រឹទ្ធសភា និងបានព្រមព្រៀងគ្នាលើដំណោះស្រាយនយោបាយ ដែលមានខ្លឹមសារដូចខាងក្រោម៖

**ប្រការ ១.-**

គណបក្សទាំងពីរបានឯកភាពគ្នាលើដំណោះស្រាយនយោបាយដោយចូលរួមធ្វើការជាមួយគ្នានៅក្នុងស្ថាប័នរដ្ឋសភា ដើម្បីឈានទៅដោះស្រាយបញ្ហានានារបស់ប្រទេសជាតិ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

**ប្រការ ២.-**

ផ្អែកតាមស្មារតីនៃសេចក្តីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ គណបក្សទាំងពីរបានឯកភាពគ្នាដើម្បីកែទម្រង់ការបោះឆ្នោតដោយរៀបចំស្ថាប័នរៀបចំការបោះឆ្នោតជាស្ថាប័ន ដែលមានឯករាជ្យពេញលេញដោយមានចែងក្នុងជំពូកមួយដោយឡែកក្នុងរដ្ឋធម្មនុញ្ញ ហើយសមាសភាពនៃស្ថាប័ននេះ ត្រូវជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានចំនួន ០៩ រូប ក្នុងនោះ សមាសភាព ០៤ រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល, សមាសភាព ០៤ រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ហើយសមាសភាព ០១ រូបទៀត គឺត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្ស ដែលមានអាសនៈក្នុងរដ្ឋសភា។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ត្រូវដំណើរការរៀបចំឱ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជូនរដ្ឋសភាដើម្បីបោះឆ្នោតទុកចិត្ត។ ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែល

មានស្រាប់ត្រូវបន្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានថវិកាស្វយ័តសម្រាប់ដំណើរការ។

គណបក្សទាំងពីរឯកភាពគ្នាឱ្យគណៈកម្មការចម្រុះដែលមានស្រាប់ បន្តពិភាក្សាគ្នារៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ស្របតាមសេចក្តីប្រកាសរួមរវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ក្នុងនោះ ដោយរួមទាំងការរៀបចំបញ្ជីឈ្មោះបោះឆ្នោតជាថ្មី។

**ប្រការ ៣.-**

គណបក្សទាំងពីរឯកភាពគ្នាកំណត់ឡើងវិញ នូវកាលបរិច្ឆេទសម្រាប់ការបោះឆ្នោតនាពេលខាងមុខ។

**ប្រការ ៤.-**

គណបក្សទាំងពីរឯកភាពគ្នាក្នុងការរៀបចំឱ្យមានការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ គណបក្សទាំងពីរឯកភាពគ្នាធ្វើការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីឱ្យស្ថាប័ននេះអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធភាព ក្នុងនោះ លើកកំពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណបក្សទាំងពីរឯកភាពគ្នារៀបចំក្បាលម៉ាស៊ីនរដ្ឋសភា ដោយបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការ អចិន្ត្រៃយ៍នៃរដ្ឋសភា តាមរូបមន្ត ៧ ទល់ ៦ ដោយត្រូវបង្កើតបន្ថែម គណៈកម្មការជំនាញថ្មីមួយទៀត ហើយដោយមានប្រធានរដ្ឋសភាមកពីគណបក្សប្រជាជនកម្ពុជា, អនុប្រធានទី ១ មកពីគណបក្សសង្គ្រោះជាតិ និងអនុប្រធានទី ២ មកពីគណបក្សប្រជាជនកម្ពុជា។ គណៈកម្មការដែលបង្កើតថ្មីជាគណៈកម្មការទី ១០ មានឈ្មោះថា "គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ" ដោយបំបែកចេញពីគណៈកម្មការទី ៤ ហើយដូរឈ្មោះគណៈកម្មការទី ៤ មកជា "គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ"។ គណៈកម្មការដែលគណបក្សប្រជាជនកម្ពុជាធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី ២, គណៈកម្មការទី ៤, គណៈកម្មការទី ៥, គណៈកម្មការទី ៦ និងគណៈកម្មការទី ៩។ គណៈកម្មការដែលគណបក្សសង្គ្រោះជាតិធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី ១, គណៈកម្មការទី ៣, គណៈកម្មការទី ៧, គណៈកម្មការទី ៨ និង គណៈកម្មការទី ១០។ គណៈកម្មការនីមួយៗមាន ០៩ រូប។ គណៈកម្មការដែលគណបក្សណាធ្វើជាប្រធាន គណបក្សនោះមាន ០៥ រូប និងគណបក្សមួយទៀតមាន ០៤ រូប។

**ប្រការ ៥.-**

គណបក្សទាំងពីរឯកភាពគ្នាពិនិត្យរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា។

**ប្រការ ៦.-**

គណបក្សទាំងពីរឯកភាពគ្នាធ្វើការកែទម្រង់ និងពង្រឹងស្ថាប័នជាតិសំខាន់ៗ ជាពិសេសស្ថាប័នឯករាជ្យនានាឱ្យអាចបំពេញការងារបម្រើជាតិ និងប្រជាពលរដ្ឋ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ។

**ប្រការ ៧.-**

គណបក្សទាំងពីរឯកភាពគ្នាក្នុងការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទដ្ឋានគតិយុត្ត ពាក់ព័ន្ធដើម្បីជានាការអនុវត្តកិច្ចព្រមព្រៀងនេះ។

| | |
|---|---|
| **តំណាងគណបក្សប្រជាជនកម្ពុជា** | **តំណាងគណបក្សសង្គ្រោះជាតិ** |
| **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** | **ឯកឧត្តម សម រង្ស៊ី** |

| | | | |
|---|---|---|---|
| **ឯកឧត្តម សាយ ឈុំ** | **ឯកឧត្តម ស ខេង** | **ឯកឧត្តម កឹម សុខា** | **ឯកឧត្តម ប៉ុល ហំម** |